# បណ្ណលេខ១(ក)៖ បូរ៉ាស្វែងរកការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ






យុវជន**បូរ៉ា**អាយុ១៧ឆ្នាំគឺមានអូទីស្ស៊ីម។គាត់បានរៀនចប់ថ្នាក់ទី៩និងបានចុះឈ្មោះចូលរៀននៅមណ្ឌលបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ។ ដោយមានការណែនាំពីបុគ្គលិកសង្គម ឪពុករបស់**បូរ៉ា**បាននាំគាត់ទៅមណ្ឌលបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ ហើយគាត់ត្រូវបានគេទទួលឲ្យចូលរៀន។ **បូរ៉ា**ចូលចិត្តរៀនជំនាញដើម្បីជួយខ្លួនឯង និងមានឯករាជ្យភាព។ ដោយមានការជួយជ្រោមជ្រែងពីក្រុមគ្រួសារ និងគ្រូរបស់គាត់នៅឯមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ គាត់សង្ឃឹមថា អាចជម្នះបាននូវផលលំបាកនានា និងមានជោគជ័យក្នុងជីវិត។

# ព័ត៌មានបន្ថែម៖

កុមារអូទីស្សឹមមានបញ្ហាអាកប្បកិរិយា និងផលលំបាកផ្សេងៗ អាស្រ័យលើដំណាក់កាលនៃការអភិវឌ្ឍ ដូចជា ក្នុងវ័យពីកុមារភាព (ក្រោមអាយុ៧ឆ្នាំ) វ័យកណ្តាលនៃកុមារភាពពី ៧ ដល់ ១៤ ឆ្នាំ និងពីវ័យជំទង់ (អាយុ១៥ឆ្នាំឡើង)។

**បញ្ហាជាទូទៅមួយចំនួនដែលកើតមានទៅ តាមដំណាក់កាលអាយុជាក់លាក់ រួមមាន៖**

- វិបល្លាស បញ្ហាដេកក្នុងវ័យកុមារភាព វិបល្លាសដំណើរការញាណ និងមានបញ្ហាក្រពះពោះវៀន។
- នៅអាយុចូលរៀន មានការថប់បារម្ភ បាក់ទឹកចិត្ត វិបល្លាសខ្វះការផ្ចង់អារម្មណ៍និងរពឹស (ADHD)។
- ជំងឺប្រកាច់ អាចកើតឡើងក្នុងដំណាក់កាលណាមួយក្នុងវ័យកុមារភាព ប៉ុន្តែជាទូទៅកើតមាននៅពេលវ័យពេញជំទង់។
- ពិការផ្នែកសតិបញ្ញា គឺជាបញ្ហាកើតមានជាញឹកញាប់ដែលទាក់ទងនឹងអូទីស្សឹម ព្រោះកុមារពី៦ទៅ៧នាក់ ក្នុងចំណោម១០នាក់មានពិការផ្នែកសតិបញ្ញា។

**នេះជាឧទាហរណ៍មួយចំនួនទាក់ទងនឹងបញ្ហារួមផ្សំផ្សេងៗ ដែលកុមារអូទីស្សឹមអាចធ្លាប់មាន៖**

- **ការថប់បារម្ភ៖ ប៉ូរ៉ា**មានបទពិសោធន៍ការថប់បារម្ភ ពេលដែលគាត់ចូលរៀន ព្រោះវាជាបរិយាកាសថ្មី។ ប៉ុន្តែម្តាយរបស់**ប៉ូរ៉ា**ជូនគាត់ទៅសាលារៀន និងពិភាក្សាជាមួយគ្រូបង្រៀនអំពីបទពិសោធន៍ថប់បារម្ភរបស់កុមារអូទីស្សឹម និងធ្វើឲ្យមានការផ្លាស់ប្តូរ។

*ដោយមានការជួយគាំទ្រពីម្តាយ និងគ្រូបង្រៀន ប៉ូរ៉ាអាចបន្តការរៀនសូត្រនៅសាលារៀនបាន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 3 9/6/23 2:22 PM

# បណ្ណលេខ១(ខ)៖ បូរ៉ាស្វែងរកការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ







រឿងរ៉ាវរបស់**បូរ៉ា** គឺរំឮកថា កុមារដែលមានអូទីស្សឹម និងមានបញ្ហារួមផ្សំផ្សេងៗ អាចរៀនជំនាញ រកប្រាក់ និងមានភាពឯករាជ្យម្ចាស់ការដូចអ្នកដទៃទៀតដែរ។ ដោយមានការគាំទ្រដ៏ត្រឹមត្រូវ គេអាចសម្រេចបាននូវអ្វីដែលគេចង់បាន នៅពេលដែលគេគិតថាធ្វើវាបាន។ បញ្ហារួមផ្សំផ្សេងៗអាចធ្វើឲ្យប៉ះពាល់ដល់ការអភិវឌ្ឍរបស់កុមារ អាកប្បកិរិយា និងផលរំខានចំពោះសមត្ថភាពសិក្សារបស់គេ។ ឪពុកម្តាយអាចជួយកូនដែលមានអូទីស្សឹម និងមានបញ្ហារួមផ្សំផ្សេងៗ ដោយការស្វែងរកជំនួយឲ្យបានទាន់ពេលវេលាសមស្របពីវេជ្ជបណ្ឌិត និងគ្រូបង្រៀន ដើម្បីឲ្យកូនគាត់អាចរៀនបានចប់ និងមានលទ្ធភាពរួចរាល់ចូលរៀនជំនាញវិជ្ជាជីវៈ ដូចជា ករណីរបស់ **បូរ៉ា** ជាដើម។

3.Flashcard_Level3_Khmer_V6.indd 4 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

- **វិបល្លាសខ្វះការផ្ចង់អារម្មណ៍ និងរពឹស (ADHD)៖ ប៉ូរ៉ា** មានរោគសញ្ញាស្រាល ដោយសារគាត់មានផលលំបាកក្នុងការផ្ចង់អារម្មណ៍ និងមិនអាចអង្គុយនៅនឹងមួយកន្លែងបាន។ ដោយមានការជួយអន្តរាគមន៍នៅផ្ទះ ធ្វើឲ្យកុមារមានភាពប្រសើរឡើង។
- **ជំងឺប្រកាច់៖** ប៉ូរ៉ាមានជំងឺប្រកាច់តាំងពីអាយុ១៥ឆ្នាំ ហើយក្រុមគ្រួសារបានជួយគាត់មកមន្ទីរពេទ្យជាបន្ទាន់។ បន្ទាប់ពីការពិនិត្យ (ចង្វាក់ក្រាហ្វិកចរន្តអគ្គិសនីខួរក្បាល) និងការផ្តល់ថ្នាំបានសមស្រប **ប៉ូរ៉ា**បានធូរស្រាលលែងមានការប្រកាច់កាលពីពីរឆ្នាំកន្លងមកហើយ។
- **ពិការភាពបញ្ញា (ID)៖** កុមារអូទីស្សឹមមានពិការផ្នែកសតិបញ្ញា ដែលអាចប៉ះពាល់ដល់សមត្ថភាពយល់ដឹងរបស់គេ។ ប៉ូរ៉ាមានបញ្ហាយល់ដឹងកម្រិតស្រាល អញ្ចឹងហើយបានជាមានផលលំបាកទទួលការអប់រំនៅមហាវិទ្យាល័យ។

*បើទោះជាមានបញ្ហារួមផ្សំផ្សេងៗ ដូចជា ការថប់បារម្ភ ខ្វះការផ្ចង់អារម្មណ៍ រពឹស និងមានពិការភាពបញ្ញាកម្រិតស្រាល ប៉ូរ៉ាអាចរៀនចប់ថ្នាក់ទី៩ ។ ក្រុមគ្រួសាររបស់ប៉ូរ៉ាបានធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ ដោយស្វែងរកការបណ្តុះបណ្តាលអប់រំជំនាញសម្រាប់ប៉ូរ៉ា។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 5 9/6/23 2:22 PM

# បណ្ណលេខ២(ក)៖ របៀបរៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈជាលក្ខណៈបុគ្គល







ឪពុកម្តាយ**បូរ៉ា**បានចរចាដោយជោគជ័យដោយស្នើសុំឲ្យសាលាប្រើនូវ**ប្រព័ន្ធប្រាស្រ័យទាក់ទងដោយផ្លាស់ប្តូររូបភាព** (PECS)។ ប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព នឹងជួយ**បូរ៉ា**ឲ្យរៀនជំនាញថ្មីផងដែរនៅឯមណ្ឌលបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ។

3.Flashcard_Level3_Khmer_V6.indd 6 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

**នេះជាព័ត៌មាន ដែលមានប្រយោជន៍មួយចំនួន អំពីប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព (PECS)៖**

ប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព គឺជាឧបករណ៍មួយសម្រាប់អ្នកដែលសមត្ថភាពតិចតួច ឬមិនមានសមត្ថភាពក្នុងការទំនាក់ទំនង ដូចជា កុមារអូទីស្សឹម ដើម្បីធ្វើការទំនាក់ទំនងតាមរយៈការប្រើប្រាស់រូបភាព។ អ្នកដែលប្រើប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព អាចទំនាក់ទំនងទៅកាន់បុគ្គលម្នាក់ទៀត ដោយផ្តល់រូបភាពទៅគេ និងទទួលអ្វីមួយដែលខ្លួនចង់បានដោយការផ្លាស់ប្តូររូបភាពនោះ។ ការធ្វើដូចនេះ បុគ្គលនោះអាចផ្តួចផ្តើមឲ្យមានការទំនាក់ទំនង។ កុមារ ឬមនុស្សធំមានអូទីស្សឹម អាចប្រើប្រាស់ប្រព័ន្ធផ្លាស់ប្តូរទំនាក់ទំនងតាមរយៈផ្លាស់ប្តូររូបភាព ដើម្បីធ្វើការទំនាក់ទំនង ឬស្នើសុំ ផ្តល់គំនិត ឬក៏អ្វីមួយដែលអាចបង្ហាញ ឬធ្វើជានិមិត្តរូបនៅលើកាតរូបភាព។ ប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព អាចធ្វើបានល្អពេលនៅផ្ទះ ឬក្នុងថ្នាក់រៀន។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 7 9/6/23 2:22 PM

# បណ្ណលេខ២(ខ)៖ របៀបរៀន និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈជាលក្ខណៈបុគ្គល







ឪពុកម្ដាយរបស់**បូរ៉ា** អនុវត្តការប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្ដូររូបភាពនេះយ៉ាងសកម្ម ដោយការរំលឹកឡើងវិញ និងចំណាយពេលវេលាច្រើនជាមួយ**បូរ៉ា**។ ពួកគាត់សរសើរ**បូរ៉ា**នៅពេល**បូរ៉ា**អនុវត្តតាម និងទទួលបានជោគជ័យ និងមានមោទនភាពចំពោះអ្វីដែល**បូរ៉ា**បញ្ចប់កិច្ចការបានទៅតាមផែនការ។ ដោយសារឪពុកម្ដាយរបស់គាត់សរសើរគាត់ភ្លាមៗ នៅពេលគាត់បានធ្វើកិច្ចការចប់ **បូរ៉ា**តែងតែចង់ធ្វើបន្ថែមទៀត។

# ព័ត៌មានបន្ថែម៖

**ព័ត៌មានខាងក្រោមនេះអាចជួយក្នុងការបង្កើតកាលវិភាគជារូបភាព ឬ ប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព៖**

- ប្រើភាសាច្បាស់ និងសាមញ្ញងាយយល់
- ប្រើរូបភាព និងនិមិត្តសញ្ញា ដែលកូនលោកអ្នកអាចយល់បាន
- ធ្វើកាលវិភាគងាយៗតាមដែលអាចធ្វើបាន
- ធ្វើការរំលឹកកាលវិភាគជាមួយកូនរបស់អ្នកឲ្យបានទៀងទាត់
- មានការអត់ធ្មត់ និងត្រូវធ្វើជាទៀងទាត់
- សរសើរកូនដែលអនុវត្តតាមកាលវិភាគជារូបភាព

*បូរ៉ាធ្លាប់បានប្រើប្រាស់កាលវិភាគជារូបភាព ដើម្បីបំពេញកិច្ចការរបស់គាត់ ក៏ដូចជាទំនាក់ទំនងជាមួយអ្នកដទៃដោយប្រើប្រាស់ប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព។ ដោយសារការខិតខំប្រឹងប្រែងរបស់ឪពុកម្តាយគាត់ បូរ៉ាពេលនេះចូលរៀនជំនាញក្នុងមណ្ឌលអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ។ នេះអាចធ្វើឲ្យបុគ្គលិក បណ្តុះបណ្តាលវិជ្ជាជីវៈធ្វើការវាយតម្លៃ និងដាក់ផែនការកិច្ចការសមស្របសម្រាប់បូរ៉ា។*

*ធ្វើដូច្នេះ បូរ៉ាអាចរៀនជំនាញថ្មី និងមានភាពឯករាជ្យម្ចាស់ការក្នុងជីវិតរបស់គាត់។ ដោយមានការខិតខំប្រឹងប្រែង និងធ្វើផែនការល្អ ឪពុកម្តាយ និងគ្រូរបស់កុមារអូទីស្សឹម អាចបង្កើតកាលវិភាគជារូបភាព ឬប្រព័ន្ធប្រាស្រ័យទាក់ទងតាមរយៈផ្លាស់ប្តូររូបភាព ដែលនឹងជួយកូនរបស់គេ មិនត្រឹមតែបានរៀនជំនាញថ្មីៗនោះទេ ប៉ុន្តែថែមទាំងទទួលបានជោគជ័យក្នុងជីវិត។*


សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៣(ក)៖ ការអប់រំវិជ្ជាជីវៈ និងបណ្តុះបណ្តាល







**ប៉ូរ៉ា**បានត្រៀមខ្លួនរួចរាល់នឹងចូលរៀនជំនាញវិជ្ជាជីវៈ និងទទួលការបណ្តុះបណ្តាល ដើម្បីមានជីវិតរស់នៅដោយឯករាជ្យ។ ឪពុកម្តាយរបស់ប៉ូរ៉ាបានចុះឈ្មោះឲ្យ**ប៉ូរ៉ា**ចូលរៀនត្រៀមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញ ដោយមានការជួយជ្រោមជ្រែងរបស់អង្គការមួយ។ កម្មវិធីនេះបង្កើតឡើង ដើម្បីជួយយុវជនអូទីស្សឹម ពួកគេអាចរៀនជំនាញចាំបាច់សម្រាប់ទទួលបានការងារធ្វើ និងរស់នៅដោយឯករាជ្យខ្លួនឯង។ **ប៉ូរ៉ា**បានរៀនជំនាញផ្សេងៗ ដូចជា ជួសជុលទូរស័ព្ទ បញ្ចូលទិន្នន័យ ថតចម្លងឯកសារ និងជំនាញការងារការិយាល័យផ្សេងៗទៀត។

# ព័ត៌មានបន្ថែម៖

ការអប់រំត្រៀម និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាមធ្យោបាយដ៏ប្រសើរមួយសម្រាប់ជួយកុមារអូទីស្សឹម ដើម្បីត្រៀមទទួលបានការងារ និងឈានទៅរកជីវិតឯករាជ្យម្ចាស់ការខ្លួនឯង។ ឪពុកម្តាយជាច្រើនមិនមានសង្ឃឹមដោយសារគ្មានឱកាស និងមានការរើសអើងនឹងបញ្ហាអូទីស្សឹម។ ឪពុកម្តាយត្រូវដឹងថា បុគ្គលអូទីស្សឹមមានសមត្ថភាពរៀនបាន នៅពេលដែលការបណ្តុះបណ្តាលបានកែសម្រួលឲ្យសមស្របទៅនឹងរបៀបរៀនរបស់ពួកគេ។ ក្នុងនាមជាឪពុកម្តាយម្នាក់ លោកអ្នកអាចជួយកូនរបស់អ្នករកការងារធ្វើ ដោយធ្វើការទំនាក់ទំនងជាមួយបុគ្គលិកសង្គមកិច្ចនៅក្នុងមូលដ្ឋាន ដើម្បីឲ្យកូនអ្នកទទួលបានជំនាញចាំបាច់នៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល ឬជាស្ថាប័នរដ្ឋ។

**នេះជាព័ត៌មានមួយចំនួនសម្រាប់ជួយយុវជនអូទីស្សឹម ដើម្បីត្រៀមទទួលបានការងារធ្វើ៖**

- **ស្វែងរកស្ថាប័នដែលនៅជិតកន្លែងអ្នកកំពុងរស់នៅ៖** ឪពុកម្តាយអាចជួយកូនរបស់គាត់ដោយធ្វើការទំនាក់ទំនងជាមួយអង្គការក្នុង ស្រុក ស្ថាប័នរដ្ឋ ឬឯកជន ដើម្បីរៀនជំនាញដែលចាំបាច់ សម្រាប់ការងារ សហការណ៍ជាមួយអ្នកផ្សេងៗទៀត និងធ្វើតាមការណែនាំ (ដូចឪពុកម្តាយរបស់**បូរ៉ា**បានធ្វើ)។
- **ជ្រើសរើសជំនាញវិជ្ជាជីវៈដែលសមស្រប៖** យុវជនអូទីស្សឹមម្នាក់ៗ មានចំណង់ចំណូលចិត្តការងារទៅតាមកម្រិតអូទីស្សឹមរបស់គេ បញ្ហារួមផ្សំនានា និងរបៀបរៀនរបស់មនុស្សម្នាក់ៗ។ វាមានសារៈសំខាន់ដែលមានជម្រើសផ្សេងៗសម្រាប់ពួកគេ មានអារម្មណ៍ងាយស្រួល និងជ្រើសរើសជំនាញ ដូចជាក្នុងករណី**បូរ៉ា** ដែលគាត់ចូលចិត្តរៀនជំនាញការិយាល័យជាជាងការងារផ្ទះ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 11 9/6/23 2:22 PM

# បណ្ណលេខ៣(ខ) ៖ ការអប់រំវិជ្ជាជីវៈ និងបណ្តុះបណ្តាល






គាត់បានទទួលការបណ្តុះបណ្តាលជំនាញសង្គម និងបំណិនជីវិត។ គាត់បានគេផ្តល់ឱកាសឲ្យរៀនពីការចម្អិនអាហារ ការងារសម្អាត និងបោកគក់ជាដើម។ល។ ប៉ុន្តែគាត់ចូលចិត្តរៀនជំនាញការិយាល័យជាងការងារផ្ទះ។ គាត់ក៏បានរៀនពីរបៀបទំនាក់ទំនងជាមួយនឹងអ្នកនៅកន្លែងការងារផងដែរ។ ឪពុកម្តាយរបស់**ប៊ូរ៉ា** គ្រូ និងមិត្តរួមការងាររបស់**ប៊ូរ៉ា**ផ្តល់ការគាំទ្រគាត់ ហើយជួយឲ្យគាត់រៀននូវជំនាញដែលចាំបាច់។ រឿងរ៉ាវរបស់ប៊ូរ៉ាគឺជាឧទាហរណ៍មួយពីរបៀបការបណ្តុះបណ្តាលជំនាញដែលសមស្របជាការចាប់អារម្មណ៍ចំពោះបុគ្គលអូទីស្សឹមម្នាក់ៗដើម្បីរៀបចំត្រៀមខ្លួនគេឆ្ពោះទៅរកភាពជោគជ័យក្នុងអាជីព។

3.Flashcard_Level3_Khmer_V6.indd 12 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

- **កែសម្រួលសម្ភារៈបណ្ដុះបណ្ដាល តម្រូវនឹងបុគ្គលអូទីស្សឹមម្នាក់ៗ:** បុគ្គលអូទីស្សឹមម្នាក់ៗមានជំនាញយល់ដឹងផ្សេងៗគ្នា រយៈពេលការផ្ចង់អារម្មណ៍ និងសមត្ថភាពរាងកាយ។ ដូចនេះគ្រូបណ្ដុះបណ្ដាលត្រូវធ្វើការកែប្រែ និងសម្របសម្រួលទៅតាមតម្រូវការរបស់បុគ្គលដែលមានអូទីស្សឹមម្នាក់ៗ។
- **ជួយកូនដើម្បីអភិវឌ្ឍជំនាញសង្គមរបស់គេៈ** ជំនាញសង្គមមានសារៈសំខាន់សម្រាប់ជោគជ័យក្នុងការងារ។ អ្នកអាចជួយកូន ដើម្បីអភិវឌ្ឍជំនាញសង្គម ដោយលើកទឹកចិត្តគេ ឲ្យចូលរួមក្នុងសកម្មភាពផ្សេងៗនៅផ្ទះ (ដូចជា ស្វាគមន៍ភ្ញៀវ- និយាយពាក្យជម្រាបសួរ) និងនៅទីសាធារណៈ ដូចជា និយាយពាក្យ អរគុណ និងនៅទីផ្សារ ពេលទិញសម្ភារៈអ្វីមួយ ឬក៏ចូលរួមក្នុងសកម្មភាពកីឡា (ហែលទឹក)។
- **សារៈសំខាន់ក្នុងការអភិវឌ្ឍជំនាញសង្គម និងប្រាស្រ័យទាក់ទងនៅកន្លែងការងារៈ** ជំនាញប្រាស្រ័យទាក់ទងគឺមានសារៈសំខាន់ផងដែរ ដើម្បីទទួលបានជោគជ័យនៅកន្លែងការងារ។ គ្រូបង្វឹកការងារ គួរតែបង្កើតឱកាសជាក់លាក់សម្រាប់យុវវ័យដែលមានអូទីស្សឹម ដើម្បីអភិវឌ្ឍជំនាញសង្គម និងការប្រាស្រ័យទាក់ទងរបស់គេ ដោយលើកទឹកចិត្តពួកគេឲ្យចូលរួម ក្នុងកិច្ចសន្ទនា និងសកម្មភាពទាំងអស់នៅក្នុងមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

*កិច្ចសហការល្អរវាងក្រុមគ្រួសារ និងបុគ្គលិកបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីធ្វើផែនការ និងវាយតម្លៃឲ្យបានញឹកញាប់លើការវិវត្ត និងកែសម្រួលកម្មវិធីបណ្ដុះបណ្ដាល ដើម្បីឲ្យសមស្របទៅនឹងចំណូលចិត្ត និងក្ដីប្រាថ្នារបស់យុវជនអូទីស្សឹមម្នាក់ៗ នឹងជួយគេឲ្យបានទទួលលទ្ធផលជោគជ័យ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 13 9/6/23 2:22 PM

# បណ្ណលេខ៤(ក)៖ បញ្ហាអាកប្បកិរិយានៅកន្លែងការងារ (អាកប្បកិរិយាផ្លូវភេទ)







**ប៉ូរ៉ា**បង្ហាញអាកប្បកិរិយាផ្លូវភេទមិនសមរម្យនៅទីសាធារណៈ។ ឪពុកម្តាយ**ប៉ូរ៉ា**បានដឹងថា **ប៉ូរ៉ា**បានបង្ហាញអាកប្បកិរិយាមិនសមរម្យនៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយគាត់ប៉ះ និងលេងជាមួយប្រដាប់ភេទរបស់គាត់។ ស្ថានភាពនោះបានធ្វើឲ្យឪពុកម្តាយគាត់មានការព្រួយបារម្ភ។ ពួកគាត់ជួបគ្រូពេទ្យ ចិត្តវិទ្យា ដែលធ្លាប់បានស្គាល់**ប៉ូរ៉ា**ពីមុន។ គ្រូពេទ្យចិត្តវិទ្យាបានពន្យល់ថា នេះជាដំណាក់កាលវិវត្តធម្មតា ហើយកុមារទាំងអស់បង្ហាញភាពឯកជនរបស់គេ។

# ព័ត៌មានបន្ថែម៖

## ការយល់ដឹងអំពីបញ្ហាអាកប្បកិរិយាក្នុងចំណោមយុវវ័យដែលមានអូទីស្សឹម និងការជួយពួកគេៈ

- **ត្រូវមានចិត្តអត់ធ្មត់ និងមានការយោគយល់ៈ** វាមានសារៈសំខាន់ដែលត្រូវអត់ធ្មត់ និងយោគយល់ដល់យុវវ័យដែលមានអូទីស្សឹម ជាពិសេស នៅពេលគេមានបញ្ហាអាកប្បកិរិយា ដែលមិនសមស្របជាមួយនឹងការរំពឹងទុករបស់សាធារណៈជន។
- **កត់សម្គាល់អំពីបរិបទ និងកត្តាបង្កហេតុៈ** តើអ្វីដែលបណ្ដាលឲ្យមានបញ្ហាអាកប្បកិរិយា? នៅពេលដែលអ្នកដឹងពីការបង្កហេតុ អ្នកអាចធ្វើការកែប្រែវា ឬក៏ធ្វើផែនការដើម្បីដោះស្រាយបញ្ហានោះ។ ក្នុងករណីរបស់**បូរ៉ា** បញ្ហាអាកប្បកិរិយាគឺទាក់ទងទៅនឹងដំណាក់កាលអភិវឌ្ឍន៍របស់គាត់។ ការផ្លាស់ប្ដូរអ័រម៉ូនរបស់គាត់ជំរុញឲ្យគាត់មានអាកប្បកិរិយាមិនសមរម្យ។
- **កំណត់ការរំពឹងទុកឲ្យបានច្បាស់លាស់ៈ** វាមានសារៈសំខាន់ដើម្បីឲ្យយុវវ័យដឹងនូវអ្វីជាក្ដីរំពឹង នៅក្នុងស្ថានភាពផ្សេងៗគ្នា។ ធ្វើដូចនេះគឺជួយពួកគេឲ្យយល់ពីអាកប្បកិរិយាដែលទទួលយកបាន និងអ្វីដែលមិនទទួលយកបាន ហើយផ្លាស់ប្ដូរអាកប្បកិរិយានោះ។ ឪពុកម្ដាយរបស់**បូរ៉ា** ដោយមានការណែនាំពីអ្នកព្យាបាល បានធ្វើឲ្យមានភាពច្បាស់លាស់ចំពោះ**បូរ៉ា**ថា មិនមានបញ្ហាអ្វីទេដែលបង្ហាញពីភេទជាលក្ខណៈឯកជនតែមិនមែននៅកន្លែងសាធារណៈនោះទេ។
- **ប្រើប្រាស់រូបភាពដើម្បីធ្វើការប្រាស្រ័យទាក់ទងៈ** កុមារអូទីស្សឹមរៀនប្រសើរបំផុតតាមរយៈការមើល ដូច្នេះ ការប្រើប្រាស់រូបភាពជាជំនួយអាចជាមធ្យោបាយដ៏ល្អបំផុតដើម្បីជួយគេឲ្យយល់ពីការណែនាំ និងកិច្ចការដែលត្រូវធ្វើ។ ឪពុកម្ដាយរបស់**បូរ៉ា**ប្រើប្រាស់រូបភាពនៅក្នុងបន្ទប់ទឹករបស់**បូរ៉ា** ដើម្បីបញ្ជាក់ថាការបង្ហាញពីភាពឯកជន គឺអាចអនុញ្ញាតធ្វើបាននៅក្នុងកន្លែងឯកជនខ្លួនឯង និងមិនមែននៅក្នុងទីសាធារណៈនោះទេ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 15 9/6/23 2:22 PM

# បណ្ណលេខ៤(ខ)៖ បញ្ហាអាកប្បកិរិយានៅកន្លែងការងារ (អាកប្បកិរិយាផ្លូវភេទ)




គ្រូពេទ្យចិត្តវិទ្យាបានពន្យល់ របៀបបង្រៀន**ប៉ូវ៉ា**អំពីភាពខុសគ្នារវាងកន្លែងសាធារណៈ (កន្លែងធ្វើការ ឬទីផ្សារ។ល។) និងកន្លែងឯកជន (ដូចជាក្នុងបន្ទប់គេង ឬបន្ទប់ទឹក និងនៅផ្ទះ) និងធ្វើឲ្យគាត់យល់ថា ការធ្វើសកម្មភាពហ្នឹង គឺអាចធ្វើបាននៅកន្លែងឯកជនមិនមែននៅកន្លែងសាធារណៈនោះទេ។ **ប៉ូវ៉ា**អាចឃាត់ចិត្តខ្លួនគាត់ដោយការលេងកេរ្តិ៍ខ្មាស់របស់គាត់នៅក្នុងបន្ទប់ទឹក ហើយអ្នកគ្រប់គ្រងរបស់គាត់រីករាយពីការរីកចម្រើនរបស់គាត់។ ជាមួយនឹងការគាំទ្រដ៏ត្រឹមត្រូវ យុវវ័យដែលមានអូទីស្សឹមអាចជំនះបាននូវបញ្ហាប្រឈមផ្សេងៗរបស់គេ ហើយសម្រេចបាននូវគោលបំណងរបស់គេ។

# ព័ត៌មានបន្ថែម៖

- **ផ្តល់ការជំរុញលើកទឹកចិត្តជាវិជ្ជមាន:** នៅពេលដែលបុគ្គលអូទីស្សឹម មានអាកប្បកិរិយាវិជ្ជមាន សូមច្បាស់លាស់សរសើរពីទង្វើរបស់គេ។ ធ្វើដូចនេះ ជួយគេឲ្យរៀនថាឥរិយាបទល្អតែងតែត្រូវបានទទួលការសរសើរ។ **ប៉ូរ៉ា**ឆាប់យល់ នៅពេលដែលឪពុកម្តាយរបស់គាត់សរសើរគាត់ ពីការបញ្ឈប់អាកប្បកិរិយាមិនល្អ។
- **អនុវត្តឲ្យបានជាប់លាប់:** វាមានសារៈសំខាន់ណាស់ដើម្បីឲ្យមានភាពជាប់លាប់ជាមួយនឹងការរំពឹងទុករបស់អ្នកទាំងនៅផ្ទះ(ទីកន្លែងឯកជន) និងកន្លែងសាធារណៈ (ឧទាហរណ៍នៅក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ)។ ធ្វើដូច្នេះ ដើម្បីជួយយុវវ័យរៀនពីអ្វីដែលជាការរំពឹងទុកចំពោះគេ និងមានអាកប្បកិរិយាសមរម្យ ដូចជា ក្នុងករណី**ប៉ូរ៉ា**ជាដើម។

*វាមានសារៈសំខាន់ក្នុងការស្វែករកជំនួយពីអ្នកជំនាញ ដើម្បីជួយយុវជនអូទីស្សឹម ជំនះនូវឧបសគ្គផ្សេងៗ ដែលកើតមានជាក់លាក់នៅក្នុងដំណាក់អភិវឌ្ឍរបស់ពួកគេម្នាក់ៗ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៥(ក)៖ ដោយធ្វើសកម្មភាពរស់នៅប្រចាំថ្ងៃគ្រប់គ្រាន់ ប៉ូរ៉ាមានអារម្មណ៍ថាខ្លួនត្រូវបានគេរាប់បញ្ចូល និងត្រៀមខ្លួនរួចរាល់សម្រាប់រៀនជំនាញវិជ្ជាជីវៈ



ផលលំបាកដ៏ធំមួយក្នុងចំណោមបញ្ហាដែល**ប៉ូរ៉ា**បានជួបប្រទះ គឺរៀនជំនាញសកម្មភាពរស់នៅប្រចាំថ្ងៃ។ ឪពុកម្ដាយ**ប៉ូរ៉ា**បានធ្វើការជាមួយអ្នកព្យាបាលគាត់ ដើម្បីធ្វើផែនការបង្រៀនគាត់ពីជំនាញសកម្មភាពរស់នៅប្រចាំថ្ងៃ។ ផែនការនោះ គឺចាប់ផ្ដើមពីជំនាញសាមញ្ញ ដូចជាដុសធ្មេញ និងលាងសំអាតដៃ។ ឪពុកម្ដាយ**ប៉ូរ៉ា**បានរៀបចំជំនាញទាំងនេះទៅជាដំណាក់កាលតូចៗ និងប្រើប្រាស់សម្ភារៈជំនួយ ដើម្បីជួយគាត់ឲ្យយល់ពីអ្វីដែលយើងចង់ឲ្យគាត់ធ្វើ។

3.Flashcard_Level3_Khmer_V6.indd 18 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

ជំនាញសកម្មភាពរស់នៅប្រចាំថ្ងៃ គឺចាំបាច់សម្រាប់បុគ្គលអូទីស្សឹម ដើម្បីទទួលបានជោគជ័យចូលរួមនៅក្នុងសង្គម ជាពិសេសចូលរួមរៀនក្នុងមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងរៀនពីកិច្ចការងារដើម្បីរស់នៅមានភាពឯករាជ្យនៅក្នុងជីវិត។ ជំនាញសកម្មភាពរស់នៅប្រចាំថ្ងៃសាមញ្ញៗមួយចំនួនគឺ ងូតទឹក ស្លៀកសម្លៀកបំពាក់ ញ៉ាំអាហារ សម្អិតសម្អាងខ្លួន និងការចូលបង្គន់។

វាមានសារៈសំខាន់ ដើម្បីកែលម្អវិធីសាស្រ្តក្នុងការបង្រៀន ទៅតាមសេចក្តីត្រូវការ និងសមត្ថភាពរបស់កុមារ។ បុគ្គលដែលមានអូទីស្សឹមមានជំនាញចលនាគ្រប់គ្រាន់(ការដើររត់និងសរសេរជាដើម)។ប៉ុន្តែគេមានផលលំបាកដើម្បីយល់ពីលំដាប់លំដោយថាតើមួយសកម្មភាពណាធ្វើមុនបន្ទាប់ និងក្រោយគេ ហើយនៅពេលណាដែលសកម្មភាពត្រូវបានបញ្ចប់។ ឧទាហរណ៍ត្រូវពាក់អាវមុនពេលបិទឡេវ។ ដើម្បីឲ្យគេងាយយល់ត្រូវមានរូបភាពជាជំនួយច្រើនជាង។ វាក៏មានសារៈសំខាន់ផងដែរ ត្រូវមានភាពជាប់លាប់នឹងប្រើរូបភាព សម្រាប់ជាជំនួយ ប្រសិនបើប្រើមិនមានការរីកចម្រើនទេ នោះអាចធ្វើការផ្លាស់ប្តូររូបភាព សម្ភារៈផ្សេងវិញ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 19 9/6/23 2:22 PM

# បណ្ណលេខ៥(ខ)៖ ដោយធ្វើសកម្មភាពរស់នៅប្រចាំថ្ងៃគ្រប់គ្រាន់ ប៉ូវ៉ាមានអារម្មណ៍ថាខ្លួនត្រូវបានគេរាប់បញ្ចូល និងត្រៀមខ្លួនរួចរាល់សម្រាប់រៀនជំនាញវិជ្ជាជីវៈ









ពីមួយឆ្នាំទៅមួយឆ្នាំ **ប៉ូវ៉ា**មានលទ្ធភាពងូតទឹកខ្លួនឯង ស្លៀកសម្លៀកបំពាក់  និងហូបអាហារខ្លួនឯងមួយជំហានម្តងៗ។ គាត់នៅ មានផលលំបាកជាមួយនឹងជំនាញស្មុគស្មាញមួយចំនួនទៀត ដូចជា ដាក់ឡេវអាវ និងចងខ្សែស្បែកជើងរបស់គាត់ ប៉ុន្តែគាត់អាចធ្វើបានខ្លះៗហើយ។  ឪពុកម្តាយ**ប៉ូវ៉ា**មានមោទនភាពចំពោះអ្វីដែល**ប៉ូវ៉ា**បានធ្វើ ហើយមិត្តភក្តិ និងគ្រូរបស់គាត់បានចូលចិត្តគាត់ ដោយសារគាត់សម្អាតខ្លួនបានល្អ។

3.Flashcard_Level3_Khmer_V6.indd 20 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

**នេះជាសារអប់រំសំខាន់មួយចំនួនសម្រាប់ការបង្រៀនជំនាញសកម្មភាពរស់នៅប្រចាំថ្ងៃដល់បុគ្គលដែលមានអូទីស្សឹម:**

- **ចូរអនុញ្ញាតឲ្យយុវវ័យអូទីស្សឹមចូលរួមក្នុងដំណើរការរៀបចំផែនការៈ** ឲ្យគេជ្រើសរើសជំនាញមួយណាដែលគេចង់រៀនដោយឲ្យជាជម្រើសដល់គេជ្រើសរើសជាឧទាហរណ៍ តើគេចង់រៀនពីការស្លៀកពាក់ ឬការសម្អិតសម្អាងខ្លួន។
- **ប្រើប្រាស់ឧទាហរណ៍ជាក់ស្តែង និងសម្ភារៈ រូបភាពជាជំនួយៈ** នៅពេលដែលអាចធ្វើបាន បង្ហាញយុវវ័យមានអូទីស្សឹម នូវជំហានដែលនាំទៅរកជំនាញដែលគេត្រូវរៀននៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់គេ។
- **ផ្តល់ឱកាសដើម្បីអនុវត្តៈ** នៅពេលដែលបុគ្គលនោះមានការអនុវត្តកាន់តែច្រើន គាត់នឹងមានភាពជឿជាក់ក្នុងការអនុវត្តជំនាញនោះបានកាន់តែប្រសើរ។
- **ធ្វើការកែសម្រួលផែនការ និងសម្ភារៈ** : រូបភាពជំនួយ ប្រសិនបើគ្មានការរីកចម្រើនក្នុងការរៀនជំនាញនោះ។
- **មានភាពវិជ្ជមាន និងការលើកទឹកចិត្តៈ** សរសើរកុមារពេលគេធ្វើអ្វីមួយបានសម្រេច ទោះជារឿងតូចតាចក៏ដោយ។

*ដោយការចំណាយពេលវេលានិងភាពអត់ធ្មត់កុមារនិងយុវវ័យដែលមានអូទីស្សឹមអាចរៀនជំនាញរស់នៅប្រចាំថ្ងៃនិងបានត្រៀមខ្លួនរួចរាល់សម្រាប់ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដើម្បីរៀនជំនាញដែលគេអាចរស់នៅដោយឯករាជ្យខ្លួនឯងបាន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ២៦(ក)៖ បូរ៉ាទៅមើលការប្រគុំតន្ត្រី (ការលើកកម្ពស់ជំនាញទំនាក់ទំនងសង្គម)









**បូរ៉ា**រៀនជំនាញទំនាក់ទំនងសង្គម តាមរយៈរូបភាព ដូចជាការជម្រាបសួរគ្នា។ គាត់ក៏បានរៀនពីការបញ្ចេញអារម្មណ៍របស់គាត់ និងយល់ពីការប្រើសញ្ញាក្នុងសង្គម។ នៅក្នុងពេលបុណ្យចូលឆ្នាំខ្មែរ មិត្តរួមថ្នាក់របស់**បូរ៉ា**បានទៅមើលការប្រគុំតន្ត្រី។ **បូរ៉ា**មានអារម្មណ៍រំភើប ប៉ុន្តែហាក់ភ័យព្រួយ។ គាត់បានដកដង្ហើមវែងៗ ហើយមានភាពសម្រាកស្ងាត់ស្ងៀម។

# ព័ត៌មានបន្ថែម៖

**ការទំនាក់ទំនងសង្គមគឺជាសមត្ថភាពប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ រួមមានដូចៈ**

- ការប្រើក្រសែភ្នែក
- ការបង្ហាញទឹកមុខ
- មើលភាសាកាយវិការ
- ការប្តូរវេនក្នុងការសន្ទនា
- ការបង្ហាញពីអារម្មណ៍
- ការយល់ពីការប្រើប្រាស់សញ្ញាក្នុងសង្គម

បុគ្គលដែលមានអូទីស្សឹមភាគច្រើន មានផលលំបាកក្នុងការទំនាក់ទំនងសង្គម។ នេះជាការលំបាកសម្រាប់ពួកគេក្នុងការបង្កើតមិត្តភក្តិថ្មីៗ ចូលរួមក្នុងសកម្មភាពសង្គម និងការទទួលបានជោគជ័យនៅសាលារៀន និងការងារ។

**មានមធ្យោបាយមួយចំនួនដើម្បីលើកកម្ពស់ការប្រាស្រ័យទាក់ទងក្នុងសង្គម៖**

- **ការបណ្តុះបណ្តាលពីជំនាញសង្គមៈ** ការបណ្តុះបណ្តាលនេះបង្រៀនបុគ្គលដែលមាន អូទីស្សឹមពីជំនាញដែលគេត្រូវការដើម្បីធ្វើការប្រាស្រ័យទាក់ទងឲ្យមានប្រសិទ្ធភាពជាមួយអ្នកដទៃ។
- **ការព្យាបាលភាសាៈ** អ្នកព្យាបាលភាសា ជួយបុគ្គលអូទីស្សឹម ឲ្យអង្គុយទល់មុខគ្នានៅពេលទំនាក់ទំនង ដើម្បីបង្កើនជំនាញក្នុងការនិយាយ និងភាសារបស់គេ។


សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្រ្តាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៦(ខ)៖ បូរ៉ាទៅមើលការប្រគុំតន្ត្រី (ការលើកកម្ពស់ជំនាញទំនាក់ទំនងសង្គម)









នេះជាពេលវេលាដ៏ល្អមួយសម្រាប់**បូរ៉ា** ប៉ុន្តែគាត់មានផលលំបាកក្នុងការបង្កើតមិត្តភក្តិថ្មីៗ។ គាត់ត្រូវការបង្កើនជំនាញសង្គមរបស់គាត់ដើម្បីបង្កើតមិត្តភក្តិថ្មីៗ។ រឿងរ៉ាវរបស់**បូរ៉ា**គឺជាការរំឭកថា បុគ្គលដែលមានអូទីស្សឹមត្រូវការពេលវេលា និងការខិតខំប្រឹងប្រែង រៀនជំនាញសង្គម និងការទំនាក់ទំនង។

3.Flashcard_Level3_Khmer_V6.indd 24 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

- **ការព្យាបាលតាមរបៀបលេង:** ការព្យាបាលតាមរបៀបលេងនេះ ជួយកុមារអូទីស្សឹម ឲ្យចេះរងចាំវេនគ្នា និងរៀននូវរបៀបទំនាក់ទំនងជាមួយអ្នកដទៃ។

**នេះជាព័ត៌មានបន្ថែមសម្រាប់លើកកម្ពស់ក្នុងការទំនាក់ទំនងសង្គមដល់កុមារដែលមានអូទីស្សឹម:**

- **ឆាប់ចាប់ផ្ដើម:** បើអ្នកឆាប់ចាប់ផ្ដើមអនុវត្តជំនាញទំនាក់ទំនងសង្គម នេះកាន់តែប្រសើរ។
- **អនុវត្តន៍ដោយមានភាពរីករាយ:** រៀនដោយភាពរីករាយជាមួយកុមារ។ រកវិធីដើម្បីធ្វើសកម្មភាពទំនាក់ទំនងសង្គម ដោយមានលក្ខណៈរីករាយ និងមានការចូលរួម។
- **មានភាពអត់ធ្មត់:** ការរៀនជំនាញថ្មីត្រូវការពេលវេលា។ ត្រូវមានការអត់ធ្មត់ជាមួយកូនរបស់អ្នក និងសូមកុំមានការបាក់ទឹកចិត្ត ប្រសិនបើគេមិនបានរៀនចេះគ្រប់មុខ។
- **សរសើរកូនពីភាពជោគជ័យរបស់កូន:** នៅពេលកូនធ្វើអ្វីមួយបានល្អ ត្រូវសរសើរគេ។ ធ្វើដូចនេះដើម្បីលើកទឹកចិត្តគេបន្តការខិតខំប្រឹងប្រែង និងដើម្បីរៀនពីកំហុសរបស់គេ។

*ដោយមានការចំណាយពេលវេលា និងមានភាពអំណត់ បុគ្គលអូទីស្សឹមអាចរៀនជំនាញដែលគេត្រូវការ ដើម្បីប្រាស្រ័យទាក់ទងឲ្យមានប្រសិទ្ធភាពជាមួយអ្នកដទៃ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៧(ក) ៖ សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្តាយ និងការយល់ព្រម សម្រាប់ការបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ និងរកការងារធ្វើ







ដោយសារ **បូរ៉ា** មានអាយុកាន់តែច្រើន ឪពុកម្តាយរបស់គាត់បានចាប់ផ្តើមគិតអំពីអនាគតរបស់គាត់។ ឪពុកម្តាយរបស់បូរ៉ាបានជួបជាមួយបុគ្គលិកសង្គមដែលបានផ្តល់ព័ត៌មានអំពីឱកាសការងារផ្សេងៗសម្រាប់យុវវ័យអូទីស្សឹម។

# ព័ត៌មានបន្ថែម៖

**តួនាទីរបស់ឪពុកម្តាយនៅក្នុងការបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ និងនៅកន្លែងការងារ**

ឪពុកម្តាយកុមារអូទីស្សឹមមានតួនាទីសំខាន់ ចំពោះអនាគតកូនរបស់ពួកគាត់។ ពួកគាត់មានឱកាសពិភាក្សាជាមួយអ្នកព្យាបាល និងបុគ្គលិកសង្គម ដែលជាអ្នកគ្រប់គ្រងករណី មើលការខុសត្រូវ អំពីជម្រើសការងារផ្សេងៗដែលមានសម្រាប់បុរ៉ា។ អ្នកគ្រប់គ្រងករណីនឹងជ្រើសរើសវិជ្ជាជីវៈ ដែលត្រូវនឹងសមត្ថភាព និងចរិកលក្ខណៈរបស់គេ។ នៅក្នុងដំណាក់កាលនេះ ឪពុកម្តាយយល់ព្រមចំពោះការរៀនសូត្រធ្វើការងារ អាស្រ័យទៅលើជំនាញដែលគាត់ទទួលបាននៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ។ ឪពុកម្តាយក៏គួរគិតអំពីចំណាប់អារម្មណ៍ និងក្តីប្រាថ្នារបស់កូនគាត់ផងដែរ នៅពេលជ្រើសរើសកន្លែងការងារ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៧(ខ)៖ សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ និងការយល់ព្រម សម្រាប់ការបណ្ដុះបណ្ដាលអប់រំវិជ្ជាជីវៈ និងរកការងារធ្វើ



បន្ទាប់ពីឪពុកម្ដាយយល់ព្រម **បូរ៉ា**បានចុះឈ្មោះចូលហាត់រៀនធ្វើការងារ ហើយពេលនេះគាត់អាចចម្អិនអាហារ លាងសម្អាត និងធ្វើការបោកគក់។ គាត់ក៏បានរៀនពីរបៀបគ្រប់គ្រងលុយរបស់គាត់ និងការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។ សាច់រឿងរបស់ **បូរ៉ា**បានបង្ហាញអំពីសារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ។

3.Flashcard_Level3_Khmer_V6.indd 28 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

**នេះជាឧទាហរណ៍មួយចំនួនដែលឪពុកម្ដាយអាចគាំទ្រចំពោះការងារកូនរបស់គាត់៖**

- ចូលរួមក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ កូនរបស់អ្នក។
- ស្វែងរកអ្នកផ្ដល់ការបណ្តុះបណ្តាលអប់រំវិជ្ជាជីវៈ ដែលមានបទពិសោធន៍ ធ្វើការជាមួយមនុស្សអូទីស្សឹម។ ធ្វើដូចនេះដើម្បីធានាថាកូនរបស់អ្នកបានទទួលការគាំទ្រចំពោះជំនាញដែលគេត្រូវរៀន។
- ពិភាក្សាគ្នាជាមួយអ្នកគ្រប់គ្រងករណីកូនលោកអ្នក (បុគ្គលិកសង្គមកិច្ច) នៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អំពីតម្រូវការរបស់គេ និង ជម្រើសផ្សេងៗមុនពេលជ្រើសរើសការងារ។
- ធ្វើការជាមួយគ្រូបង្វឹកកូនរបស់អ្នក និងអ្នកគ្រប់គ្រងករណី ដើម្បីធ្វើផែនការថែទាំសុខភាព និងផែនការការងារ ដែលអាចបំពេញតម្រូវការរបស់គេ។ ធ្វើដូច្នេះ អាចជួយឲ្យកូនរបស់អ្នកមានសុខភាពល្អ និងអាចចូលរួមនឹងការងារដែលគេពេញចិត្ត។
- បង្ហាញគេឲ្យឃើញថា លោកអ្នកជឿជាក់លើសមត្ថភាពរបស់គេ ហើយគេអាចសម្រេចបានជោគជ័យក្នុងការងាររបស់គេ និងសម្រេចគោលបំណងដែលគេចង់បាន។

*តាមរយៈធ្វើការងាររួមគ្នា ឪពុកម្ដាយ និងអ្នកជំនាញ អាចជួយបុគ្គលដែលមានអូទីស្សឹមសម្រេចបានសក្ដានុពលពេញលេញរបស់គេ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៨(ក)៖ កិច្ចសហការរវាងវិស័យអប់រំ សុខាភិបាល និងសង្គមកិច្ច



គ្រូពេទ្យ



អ្នកព្យាបាល



បុគ្គលិកសង្គម



គ្រូបង្រៀន

ឪពុកម្ដាយរបស់**ប៉ូវ៉ា**បានធ្វើការយ៉ាងសកម្មជាមួយនឹងអ្នកព្យាបាលរបស់**ប៉ូវ៉ា** គ្រូបង្រៀន និងបុគ្គលិកសង្គម ដើម្បីបង្កើតផែនការសម្រាប់ការអប់រំរបស់**ប៉ូវ៉ា** និងការថែទាំសុខភាព។ **ប៉ូវ៉ា**មានភាពប្រសើរឡើងនូវបញ្ញាញាណរបស់គាត់ ហើយសាលារបស់គាត់បានផ្ដល់ឱកាសដល់គាត់ដើម្បីចូលរួមសកម្មភាពក្នុងក្រុម។ **ប៉ូវ៉ា**ក៏មានភាពប្រសើរឡើងនូវភាពរពឹសរបស់គាត់ដែលរំខានដល់ការរៀនសូត្ររបស់គាត់។ គាត់បានចូលរួមក្នុងកម្មវិធីព្យាបាល និងបង្ហាត់បង្រៀនកុមារអូទីស្សឹម និងកុមារពិការដែលមានបញ្ហាទំនាក់ទំនង ដែលបានជួយគាត់ឲ្យមានការផ្ដោតយកចិត្តទុកដាក់នៅក្នុងថ្នាក់រៀន។

3.Flashcard_Level3_Khmer_V6.indd 30 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

## កិច្ចសហការរវាងអ្នកផ្តល់សេវាកម្មផ្សេងៗគ្នា ដើម្បីទទួលលទ្ធផលជោគជ័យ

យុវវ័យដែលមានអូទីស្សឹម មានតម្រូវការផ្សេងៗគ្នា និងដូចនេះ អ្នកផ្តល់សេវាថែទាំសុខភាព អ្នកផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអ្នកគ្រប់គ្រងករណី (បុគ្គលសង្គម) ត្រូវតែចូលរួមគ្នាដើម្បីធ្វើផែនការសម្រាប់បុគ្គលម្នាក់ៗ។

- អ្នកផ្តល់សេវាថែទាំសុខភាព ធ្វើការវាយតម្លៃលម្អិត និងគាំទ្រដល់កុមារអូទីស្សឹម ដើម្បីជំនះនូវបញ្ហាសុខភាពរបស់គេ។ ពួកគេផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់ឪពុកម្តាយ ដើម្បីមានតួនាទីជាអ្នកសហព្យាបាល និងជួយកូនរបស់គេនៅផ្ទះ។
- អ្នកផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ មើលពីសមត្ថភាព ចំណុចខ្លាំង និងផលលំបាកផ្សេងៗដែលយុវវ័យអូទីស្សឹមជួបប្រទះ និងពិភាក្សាជាមួយឪពុកម្តាយរបស់គេ និងអ្នកគ្រប់គ្រងករណី ដើម្បីជ្រើសរើសការងារដែលសមរម្យ។
- ឪពុកម្តាយដើរតួជាអ្នកសហការក្នុងការព្យាបាល រៀនអំពីយុទ្ធសាស្ត្រ បទអន្តរាគមន៍ដែលសមស្របពីអ្នកព្យាបាល នៅមជ្ឈមណ្ឌល ដូចជាមជ្ឈមណ្ឌលរបស់អង្គការការីតាស-CCAMH និងធ្វើការអនុវត្តនៅផ្ទះ។ ដោយមានក្តីស្រឡាញ់ និងការគាំទ្រ ហើយនឹងការចូលរួមយ៉ាងសកម្មពីអ្នកគ្រប់គ្រងករណី ពួកគេអាចជួយយុវវ័យមានអូទីស្សឹម ទទួលបានធនធាន និងការបណ្តុះបណ្តាលដែលគេត្រូវការ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៨(ខ)៖ កិច្ចសហការរវាងវិស័យអប់រំ សុខាភិបាល និងសង្គមកិច្ច









ដោយមានការជួយពីឪពុកម្តាយ គ្រូបង្រៀន និងអ្នកព្យាបាល បូរ៉ាមានការរីកចម្រើនច្រើន មានមិត្តភក្តិ និងបានចូលរួមក្នុងក្លឹបសកម្មភាពកីឡានៅសាលារៀន។ សាច់រឿងរបស់បូរ៉ាបង្ហាញពីចំណុចសំខាន់នៃការសហការណ៍រវាងឪពុកម្តាយ គ្រូបង្រៀន អ្នកព្យាបាល និងបុគ្គលិកសង្គម ដែលបានធ្វើការរួមគ្នា បង្កើតផែនការជួយជាលក្ខណៈបុគ្គលម្នាក់ៗ។

# ព័ត៌មានបន្ថែម៖

ប្រសិនបើអ្នកជាឪពុកម្តាយរបស់កុមារមានអូទីស្សឹម ជាការសំខាន់ណាស់ ដែលអ្នកត្រូវយល់ដឹងពីកិច្ចសហការយ៉ាងសកម្មរវាងផ្នែកសុខាភិបាល អប់រំ និងសង្គមកិច្ច។

**នេះជាព័ត៌មានបន្ថែមមួយចំនួន៖**

- ត្រូវធ្វើការទំនាក់ទំនងឲ្យបានទូលំទូលាយ បង្ហាញពីផលលំបាករបស់កូនអ្នក និងតម្រូវការផ្សេងៗ ទៅទាំងអ្នកព្យាបាល និងគ្រូ។
- ធ្វើការជាមួយនឹងអ្នកព្យាបាលរបស់កុមារ និងអ្នកគ្រប់គ្រងករណី ដើម្បីរៀបចំផែនការថែទាំសុខភាព ដែលរួមទាំងការបញ្ជូនត្រឹមត្រូវ នៅពេលកុមារជួបបញ្ហាថ្មីៗ ដូចជា បញ្ហារពឹស ជំងឺប្រកាច់ និងបញ្ហាគេង។ល។
- នៅពេលជ្រើសរើសអ្នកផ្តល់សេវាអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈចាំបាច់ត្រូវពិភាក្សាលម្អិតជាមួយអ្នកគ្រប់គ្រងករណី(បុគ្គលិកសង្គម) អំពីប្រភេទគាំទ្រដែលគេត្រូវការដើម្បីទទួលបានជោគជ័យ ក៏ដូចជាចំណុចដែលត្រូវអនុវត្ត ដូចជាបញ្ហាធ្វើដំណើរឆ្ងាយពីផ្ទះទៅមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៩(ក)៖ អ្នកបង្វឹកការងារ ជាអ្នកសម្របសម្រួល និងអ្នកគាំទ្រ









ឪពុកម្ដាយរបស់**បូរ៉ា**បានដឹងពីកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងបច្ចេកទេស ដែលបានផ្ដល់ដោយក្រសួងការងារ អប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា។ គ្រូបង្វឹកការងារ សម្របសម្រួលរវាងនិយោជក ឪពុកម្ដាយ និងយុវជនអូទីស្សឹម ដើម្បីរកការងារដែលសមស្របទៅនឹងជំនាញ និងចំណង់ចំណូលចិត្តរបស់**បូរ៉ា**។

# ព័ត៌មានបន្ថែម៖

## កិច្ចសហការដើម្បីទទួលបានជោគជ័យនៅកន្លែងការងារ

បុគ្គលអូទីស្សឹមអាចទទួលបានជោគជ័យនៅកន្លែងការងារបាន ដោយមានកិច្ចសហការយ៉ាងសកម្ម និងការរៀបចំផែនការដ៏មានប្រសិទ្ធភាព រវាងនិយោជក គ្រូបង្វឹកការងារ ឪពុកម្ដាយ និងបុគ្គលអូទីស្សឹមខ្លួនឯង។

- **និយោជកៈ** គួរតែត្រៀមខ្លួនរួចរាល់សម្រាប់ឲ្យបុគ្គលអូទីស្សឹមធ្វើការនៅក្នុងកន្លែងការងារ។ វាមានសារៈសំខាន់ក្នុងការផ្តល់ការងារដែលសមស្របនឹងជំនាញ និងសមត្ថភាពរបស់គេ ក៏ដូចជាមានការណែនាំតាមរយៈរូបភាពសមស្រប។
- **គ្រូបង្វឹកការងារៈ** គួរតែពិនិត្យឲ្យបានញឹកញាប់អំពីការអនុវត្តការងាររបស់គេ និងផ្តល់ការគាំទ្រដែលចាំបាច់។ នៅពេលចាំបាច់ ត្រូវពិនិត្យមើលកាលវិភាគជារូបភាព និងធ្វើវាឲ្យមានលក្ខណៈសាមញ្ញ ជាជំហាន ប្រសិនបើបុគ្គលអូទីស្សឹមមានផលលំបាកក្នុងការធ្វើតាមការណែនាំ។ គ្រូបង្វឹកការងារ សម្របសម្រួលរវាងនិយោជក និងក្រុមគ្រួសារ ដើម្បីឲ្យបុគ្គលអូទីស្សឹមអាចសម្រេចជោគជ័យនៅកន្លែងការងារ និងនៅតែបំពេញការងារបាន។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៩(ខ)៖ អ្នកបង្វឹកការងារ ជាអ្នកសម្របសម្រួល និងអ្នកគាំទ្រ






ការងារដែលផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល បានធ្វើឲ្យ**បូរ៉ា**មានសេដ្ឋកិច្ចសមរម្យគ្រប់គ្រាន់សម្រាប់ខ្លួនឯង។ ឪពុកម្តាយ គ្រូបង្វឹក ការងារ និងនិយោជក បានជួបគ្នាជាទៀងទាត់ដើម្បីពិភាក្សាគ្នាពីការរីកចម្រើនរបស់**បូរ៉ា** និងប្រាកដថាគាត់នៅតែបន្តការងាររបស់គាត់។ សាច់រឿងរបស់**បូរ៉ា**គឺជាការជំរុញទឹកចិត្ត ដែលបង្ហាញពីសារៈសំខាន់នៃកិច្ចសហការណរវាងស្ថាប័នពាក់ពន្ធ័ទៅវិញទៅមក។

3.Flashcard_Level3_Khmer_V6.indd 36 9/6/23 2:22 PM

# ព័ត៌មានបន្ថែម៖

- **ឪពុកម្តាយៈ** គួរយល់ដឹងអំពីព្រំដែនកំណត់របស់កូន និងមិនទាមទារ ឬរំពឹងទុកខ្ពស់ពេកនោះទេ។ ដោយធ្វើការទំនាក់ទំនងជាមួយគ្រូបង្វឹកការងារឲ្យបានជាប់លាប់ គេអាចជួយផ្តល់ការគាំទ្រផ្នែកស្មារតី និងការគាំទ្រផ្សេងៗទៀតដល់យុវជនអូទីស្សឹមដើម្បីឲ្យគេមានការពេញចិត្ត និងបន្តការងាររបស់គេ។
- **បុគ្គលអូទីស្សឹមៈ** គឺទៀងត្រង់ មកធ្វើការងារទៀងពេល និងខិតខំធ្វើការងារ។ ទោះបីជាយ៉ាងណាក៏ដោយ គឺពួកគេអាចមានបញ្ហាប្រឈមក្នុងការរៀនជំនាញថ្មី។ ដោយមានការគាំទ្រគ្រប់គ្រាន់ និងការយល់ដឹង យោគយល់ពីនិយោជក និងគ្រូបង្វឹកការងារ គេនឹងទទួលបានជោគជ័យនៅកន្លែងការងារ។

*ដោយធ្វើការងាររួមគ្នារវាងនិយោជក គ្រូបង្វឹកការងារ និងឪពុកម្តាយ*
*បុគ្គលអូទីស្សឹមអាចបំពេញការងារបានល្អដូចអ្នកដទៃទៀតដែរ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ១០(ក)៖ បញ្ហារៀបការ ការរស់នៅជាមួយគ្នា និង រស់នៅដោយឯករាជ្យម្ចាស់ការ







**ប៊ូរ៉ា**បានជួបនារីម្នាក់ឈ្មោះ **អារីយ៉ា** នៅកន្លែងធ្វើការងាររបស់គាត់។ ឪពុកម្តាយរបស់គាត់ឆ្ងល់ថា តើ**អារីយ៉ា**អាចរស់នៅជាមួយកូនប្រុសរបស់គាត់ ហើយផ្តល់ការគាំទ្រដែលចាំបាច់សម្រាប់**ប៊ូរ៉ា**ដោយរបៀបណា។ ឪពុកម្តាយរបស់**ប៊ូរ៉ា** បានជួបជាមួយនឹងអ្នកប្រឹក្សាយោបល់របស់**ប៊ូរ៉ា** ដែលបានពន្យល់ដល់**អារីយ៉ា** និងឪពុកម្តាយរបស់នាងអំពីសារៈសំខាន់ ដែលត្រូវយល់ពីលក្ខណៈស្ថានភាពរបស់**ប៊ូរ៉ា**។ ឪពុកម្តាយរបស់**ប៊ូរ៉ា** និង**អារីយ៉ា** មានឆន្ទៈធ្វើការរួមគ្នា ដើម្បីគាំទ្រពួកគេទាំងពីរនាក់ឲ្យបានរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។

# ព័ត៌មានបន្ថែម៖

បញ្ហារៀបការ ការរស់នៅជាមួយគ្នាជាដៃគូ និងរស់នៅដោយឯករាជ្យម្ចាស់ការ  បុគ្គលអូទីស្សឹមអាចមានដៃគូ ដើម្បីឈានទៅរកអាពាហ៍ពិពាហ៍ដ៏ជោគជ័យមួយ និងរស់នៅដោយឯករាជ្យម្ចាស់ការជាមួយនឹងការគាំទ្រដ៏ត្រឹមត្រូវ។

- **អាពាហ៍ពិពាហ៍ និងភាពជាដៃគូ៖** បុគ្គលអូទីស្សឹមដូចជា**បូរ៉ា** នៅពេលដែលគេបានទទួលការងារដោយជោគជ័យ គឺអាចនឹងស្វែងរកដៃគូ និងគិតពីការមានក្រុមគ្រួសារដូចអ្នកដទៃទៀតដែរ។ ទោះជាយ៉ាងណាក៏ដោយ គេអាចត្រូវការគាំទ្រពីក្រុមគ្រួសារ  និងអ្នកពិគ្រោះយោបល់ ដើម្បីនាំដៃគូជាអ្នកដែលអាចទទួលយក និងស្រឡាញ់គេដូចគ្នា។  ពួកគេអាចរៀនប្រាស្រ័យទាក់ទងពីតម្រូវការរបស់គេ និងចង់ឲ្យដៃគូរបស់គេទទួលបានការគាំទ្រសមស្របពីក្រុមគ្រួសារ និងអ្នកព្យាបាល។
- **ការរស់នៅជាមួយគ្នា និងរស់នៅដោយឯករាជ្យម្ចាស់ការ៖** បុគ្គលអូទីស្សឹមអាចរស់នៅដោយឯករាជ្យបានមានការគាំទ្រដ៏សមរម្យ។ ទោះជាយ៉ាងណាក៏ដោយ  គេត្រូវការ ការគាំទ្រពីស្ថាប័នផ្សេងៗ ដូចជា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងអ្នកគ្រប់គ្រងករណីដើម្បីរកកន្លែងសម្រាប់ពួកគេរស់នៅជាក្រុម ឬដោយឯករាជ្យខ្លួនឯង។  ពួកគេអាចរៀនពីការគ្រប់គ្រងចំណូល និងថវិការបស់គេដោយមានការជួយពីអ្នកគ្រប់គ្រងករណី។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

# បណ្ណលេខ១០(ខ)៖ បញ្ហារៀបការ ការរស់នៅជាមួយគ្នា និងរស់នៅដោយឯករាជ្យម្ចាស់ការ





**អារីយ៉ា** និងឪពុកម្តាយរបស់នាង បានជួបក្រុមឪពុកម្តាយគាំទ្រ និងចូលរួមវេទិកាអនឡាញសម្រាប់**ប៉ូរ៉ា** និង**អារីយ៉ា** ដែលគេអាចភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃទៀត ដើម្បីស្វែងយល់ពីបញ្ហាប្រឈមនៃជីវិតអាពាហ៍ពិពាហ៍។ **ប៉ូរ៉ា** និង**អារីយ៉ា**ដឹងគុណចំពោះឪពុកម្តាយរបស់គេ និយោជក គ្រូបង្វឹកការងារ និងអ្នកប្រឹក្សាយោបល់ ដែលជាអ្នកគាំទ្រដ៏ចាំបាច់សម្រាប់ជីវិតប្តីប្រពន្ធ។

# ព័ត៌មានបន្ថែម៖

- **ធនធានសម្រាប់ការស្នាក់នៅ និងរស់នៅមានភាពឯករាជ្យម្ចាស់ការៈ** នៅក្នុងបណ្តាប្រទេសដែលមានចំណូលខ្ពស់ អាជ្ញាធរមូលដ្ឋានអាចជួយបុគ្គលដែលមានអូទីស្សឹម ដើម្បីមានទីលំនៅ និងការគាំទ្រចាំបាច់ សម្រាប់ការរស់នៅដោយឯករាជ្យខ្លួនឯង។

ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធគាំទ្រពីសំណាក់ក្រុមគ្រួសារគឺមានភាពរឹងមាំជាង ជាពិសេសនៅបណ្តាប្រទេសនៅអាស៊ី ដូចជានៅប្រទេសយើងដូច្នេះហើយបុគ្គលដែលមានអូទីស្សឹមអាចរស់នៅជាមួយឪពុកម្តាយរបស់គេ រហូតដល់គេមានទំនុកចិត្តចេញទៅរស់នៅខាងក្រៅដោយមានភាពម្ចាស់ការខ្លួនឯង។ វាអាចមានលទ្ធភាព ប្រសិនបើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អាចមានផែនការធ្វើផ្ទះស្នាក់នៅជាក្រុមសម្រាប់ឲ្យបុគ្គលមានអូទីស្សឹម ឬជនមានពិការភាពផ្សេងទៀត រស់នៅជួបជុំគ្នាដោយរដ្ឋផ្តល់ទីលំនៅជូនពួកគេ ដោយប្រទេសកម្ពុជាឈានទៅរកប្រទេសដែលមានចំណូលមធ្យម។

*ដោយមានធនធាន និងការគាំទ្រសមស្របពីក្រុមគ្រួសារ អង្គការក្រៅរដ្ឋាភិបាល និង រាជរដ្ឋាភិបាល បុគ្គលដែលមានអូទីស្សឹម*
*អាចរស់នៅដោយមានភាពឯករាជ្យម្ចាស់ការខ្លួនឯងបាន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្រ្តាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 41 9/6/23 2:22 PM

# របៀបប្រើបណ្ណ (ប្រធានបទទី៣) ស្តីពីកុមារអូទីស្សឹមទទួលបានការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET)

**១). តើបណ្ណទាំងនេះនិយាយអំពីអ្វី (សារៈសំខាន់)៖**

បណ្ណទាំងនេះ ពន្យល់ពីបញ្ហាប្រឈម និងឱកាសសម្រាប់មនុស្សវ័យក្មេងដែលមានអូទីស្សឹម និងតួនាទីរបស់ឪពុកម្តាយ គ្រូបណ្តុះបណ្តាលបណ្តុះវិជ្ជាជីវៈ (TVET) គ្រូបង្វឹកការងារ និងបុគ្គលិកសង្គមក្នុងការជ្រើសរើសចូលជំនាញបណ្តុះបណ្តាលវិជ្ជជីវៈ (TVET) និងការស្វែងរកការងារសមរម្យ។

**២). តើអ្នកណានឹងទទួលបានអត្ថប្រយោជន៍ពីបណ្ណទាំងនេះ (ក្រុមគោលដៅ)?**

ឪពុកម្តាយ បុគ្គលិកសង្គម បុគ្គលិកថែទាំសុខភាពសហគមន៍ អ្នកភូមិ មេឃុំ គ្រូបណ្តុះបណ្តាលវិជ្ជាជីវៈ និងនិយោជក។

**៣). ការជូនដំណឹង និងការរៀបចំការផ្សព្វផ្សាយ (ការផ្សព្វផ្សាយនៅក្នុងសហគមន៍)៖**

- សូមជ្រើសរើសកន្លែងស្ងាត់ ប្រាប់អ្នកចូលរួមអំពីទីតាំង និងគោលបំណងនៃការប្រជុំ ។ សូមឲ្យឪពុកម្តាយ ដែលមានកូនអូទីស្សឹមដែលចូលរៀននៅសាលាចូលរួមនៅការពិភាក្សា (ធ្វើជាអ្នកដឹកនាំមិត្ត)។ សូមជូនដំណឹងដល់មេភូមិ និងឃុំអំពីគោលបំណង និងសុំអនុញ្ញាតិសម្រាប់ការជួបជុំគ្នានេះ។

**៤). របៀបប្រើបណ្ណទាំងនេះ (ដំណើរការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត):**

- គួរមានអ្នកចូលរួមចន្លោះពី១០ទៅ១៥នាក់ គឺជាការល្អបំផុត។
- ប្រសិនបើមានអ្នកចូលរួមច្រើន សូមប្រើបណ្ណពីរឈុតជាការល្អ។
- ចែកបណ្ណឲ្យអ្នកចូលរួមម្នាក់១សន្លឹក។
- ទុកពេលឲ្យពួកគាត់អាន និងពិនិត្យមើលរូបភាពដោយខ្លួនឯងសិន មុននឹងចាប់ផ្តើមពិភាក្សា។

**៥). ប្រធានបទនៅក្នុងឈុតបណ្ណកម្រិតទី៣ (មាតិកា)៖**

- **បណ្ណលេខ១:** **បូរ៉ាស្វែងរកការបណ្តុះបណ្តាលវិជ្ជាជីវៈ**
- **បណ្ណលេខ២:** របៀបរៀន និងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្ទាល់ខ្លួន

- **បណ្ណលេខ៣:** ការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- **បណ្ណលេខ៤:** បញ្ហាអាកប្បកិរិយានៅកន្លែងការងារ (ឥរិយាបទផ្លូវភេទ)
- **បណ្ណលេខ៥:** ដោយបានអនុវត្តសកម្មភាពសម្រាប់ជំនាញរស់នៅប្រចាំថ្ងៃ ប៉ូរ៉ាមានអារម្មណ៍ថាខ្លួនត្រូវបានគេរាប់អាន និងត្រៀមខ្លួនរួចរាល់សម្រាប់រៀនជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ
- **បណ្ណលេខ៦:** **ប៉ូរ៉ា**ទៅមើលការប្រគុំតន្ត្រី (ការលើកកម្ពស់ជំនាញប្រាស្រ័យទាក់សង្គម)
- **បណ្ណលេខ៧:** សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្តាយ ក្នុងការស្វែងរកការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការរកការងារធ្វើ
- **បណ្ណលេខ៨:** កិច្ចសហការរវាងវិស័យអប់រំ សុខាភិបាល និងការងារសង្គម
- **បណ្ណលេខ៩:** ការបង្វឹកការងារ ជាអ្នកសម្របសម្រួល និងអ្នកគាំទ្រ
- **បណ្ណលេខ១០:** បញ្ហារៀបការ ការរស់នៅជាមួយគ្នា និង ការរស់នៅដោយមានឯករាជ្យភាព

**៦). របៀបដឹកនាំការពិភាក្សា សង្ខេប និងបញ្ចប់ការពិភាក្សា (គោលការណ៍រៀនសូត្រតាមបែបចូលរួម)៖**

- សូមសួរអ្នកចូលរួមថា តើពួកគេអានពិនិត្យមើល និងអានបណ្ណដែលទទួលបាននោះចប់ហើយ ឬនៅ ឬត្រូវការពេលវេលាបន្ថែមទៀត។
- ពេលអ្នកចូលរួមម្នាក់ៗអានបណ្ណនេះចប់ហើយ សូមឲ្យពួកគាត់ចែករំលែកនូវរឿងរ៉ាវនៅលើបណ្ណផ្នែកខាងមុខ ដោយចាប់ផ្តើមពីអ្នកមានបណ្ណលេខមុនគេ។
- រួចហើយអ្នកសម្របសម្រួលចាប់ផ្តើមផ្តល់ព័ត៌មានបន្ថែមសម្រាប់បណ្ណនីមួយៗ (នៅផ្នែកខាងក្រោយ)
- សូមផ្តល់ឱកាសឲ្យមានការពិភាក្សាគ្នា ដូចជា ស្វែងយល់ បកស្រាយបញ្ជាក់បញ្ហាផ្សេងៗ មុននឹងចូលទៅបណ្ណបន្ទាប់ទៀត។
- សូមស្នើសុំឲ្យអ្នកចូលរួមណាម្នាក់ស្ម័គ្រចិត្តសង្ខេបនូវអ្វីដែលបានពិភាក្សាគ្នា។
- អ្នកសម្របសម្រួលឆ្លើយសំណួរ ផ្តល់ការបំភ្លឺ និងគូសបញ្ជាក់សារៈសំខាន់ៗ
- មុនបញ្ចប់ការពិភាក្សា សូមធ្វើសេចក្តីសន្និដ្ឋានលើប្រធានបទ ប្រាប់ពីពេលវេលាសម្រាប់ការណាត់ជួបប្រជុំគ្នាលើក្រោយទៀត
- អ្នកសម្របសម្រួលថ្លែងអំណរគុណដល់អ្នកចូលរួម

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

3.Flashcard_Level3_Khmer_V6.indd 43 9/6/23 2:22 PM

# សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

+៨៥៥-២៣-៧២៧-៤២៨

+៨៥៥-២៣-៧២៧-៤២៦

info@dac.org.kh

www.dac.org.kh

ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council

## មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវជន (ការីតាស ម.ស.ផ.ក)

មន្ទីរពេទ្យបង្អែកជ័យជំនះ តាខ្មៅ ខេត្តកណ្ដាល

+៨៥៥-២៣-៩៨៣-៣៤៨

+៨៥៥-៩២-៨៩៥-៤៦៦

ccamh-admin@caritascambodia.org

caritascambodia.org

www.CCAMH Cambodia

